**អង្គការសកម្មភាពដើម្បីបរិស្ថាន និងសហគមន៍**
Action for Environment and Communities (AEC)
អាស័យដ្ឋាន ៖ ភូមិម៉ុងបារាំង សង្កាត់ប្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ 026-988-983/017-655-526/012-291-381 អ៊ីម៉ែល ៖ aeccambodia@yahoo.com គេហទំព័រ ៖ www.aeccambodia.org

# ការវិភាគផលប៉ះពាល់យេនឌ័រនៅក្នុងតំបន់សម្បទានសេដ្ឋកិច្ច ដែលស្ថិតនៅក្នុងឃុំអញ្ចាញរូង និងឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

## សមាសភាពនៃយេនឌ័រក្នុងតំបន់គោលដៅ

ស្ត្រី បុរស កុមារ ជនពិការ និងមនុស្សចាស់ ព្រមទាំងស្ត្រីមេម៉ាយ ដែលប្រមាណជា ៥៥ ភាគរយ ជាស្ត្រីភេទ ក្នុងចំណោមប្រជាជនសរុបប្រមាណជា ៩.០៦៣ នាក់ ក្នុងនោះស្ត្រី ៤.៩៥៤ នាក់ នៅក្នុងឃុំអញ្ចាញរូង និងឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង (ស្ថិតិប្រជាជនឆ្នាំ ២០១៤) ហើយជាអ្នករស់នៅ និងពឹងអាស្រ័យផល និងអនុផលនៅក្នុងតំបន់នេះ ។ ពួកគាត់មិនត្រូវបានគេផ្តល់ព័ត៌មានពីការផ្តល់ដីសម្បទានសេដ្ឋកិច្ច ហើយដោះស្រាយផលប៉ះពាល់ឲ្យបានសមរម្យឡើយ ។

## ធនធានក្នុងតំបន់សម្បទានសេដ្ឋកិច្ច និងសិទ្ធិអាស្រ័យផលមុនពេលសកម្មភាពរបស់ក្រុមហ៊ុនដំណើរការ

- **ព្រៃឈើ ៖** យោងតាមផែនទីគម្របព្រៃរបស់រដ្ឋបាលព្រៃឈើឆ្នាំ ២០០២ តំបន់ដីដែលរដ្ឋាភិបាលបានផ្តល់សម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុនភាពីម៉ិក ជាតំបន់ព្រៃល្បោះ និងព្រៃពាក់កណ្តាលស្រោង ព្រមទាំងដីលំដៅដ្ឋាន និងដីអាគាររដ្ឋបាលរបស់រដ្ឋផងដែរ ។ ភាគច្រើននៃដីនោះគឺជាដីព្រៃពាក់កណ្តាលស្រោង ។
- **អនុផលព្រៃឈើ ៖** តាមរបាយការណ៍ស្រាវជ្រាវរបស់អង្គការអុកស្វាមអង់គ្លេស នៅឆ្នាំ ២០១០ ដែលចូលរួមស្រាវជ្រាវដោយអង្គការដៃគូជាច្រើនទៀត ប្រជាជននៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ដែលរស់នៅជិតតំបន់ព្រៃឈើ អាចរកចំណូលបានពីអនុផលព្រៃឈើចន្លោះពី ២០០០ ដុល្លារ ទៅ ៣០០០ ដុល្លារ ក្នុង ១ ឆ្នាំ ។ ចំណូលនេះគឺប្រមាណជាជិត ៥០ ភាគរយ ដែលគ្រួសារនីមួយៗរកបានប្រចាំឆ្នាំពីមុខរបរធ្វើស្រែ ចំការ និងការស្វែងរកអនុផលព្រៃឈើ ។ ប្រភេទនៃអនុផលព្រៃឈើក្នុងតំបន់នេះមានដូចជា រុក្ខជាតិឱសថជាច្រើនប្រភេទ ជ័រទឹក ទំពាំង ឬស្សី អុស ឈើធ្វើរបងផ្ទះ បន្លែផ្លែឈើព្រៃ សត្វសម្រាប់ជាអាហារ និងរបស់របរប្រើប្រាស់ប្រចាំថ្ងៃរបស់សហគមន៍ជាច្រើនប្រភេទ ។
- **សត្វព្រៃ ៖** ប្រជាជននៅក្នុងឃុំក្រាំងស្គារ ស្រុកទឹកផុស និងឃុំអញ្ចាញរូង ឃុំពេជចង្វារ និងឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និងឃុំក្បាលត្រាច និងឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ បានលើកឡើងស្របគ្នាថា នៅក្នុងតំបន់នេះជាតំបន់ដែលមានសត្វព្រៃជាច្រើនប្រភេទ ។ សត្វព្រៃសំខាន់ៗមានដូចជា ខ្លាដំបង ខ្លាត្រី ខ្លារខិន

ជ្រូកព្រៃ ឈ្លូស ប្រើស ក្តាន់ ទន្សោង ចចក ពស់ និងល្មូនជាច្រើនប្រភេទ ក្ងោក ព្រមទាំងបក្សីរាប់រយប្រភេទដែលបានរស់នៅក្នុងតំបន់នេះ ។

- **ការអាស្រ័យផលរបស់សហគមន៍ ៖** ប្រជាជនរស់នៅក្នុងឃុំក្រាំងស្គារ ស្រុកទឹកផុស និងឃុំអញ្ចាញរូង ឃុំពេជចង្វារ និងឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ រួមទាំងស្រុកចំនួន ៣ ទៀត ក្នុងខេត្តកំពង់ឆ្នាំង និងឃុំក្បាលត្រាច និងឃុំអន្លង់ត្នោត ស្រុកក្រគរ និងស្រុកចំនួន ២ ទៀត ក្នុងខេត្តពោធិ៍សាត់ ទាំងចាស់ទាំងក្មេង ព្រមទាំងជនពិការផងដែរនោះ ពួកគាត់មានសិទ្ធិក្នុងការទាញយកអនុផលព្រៃឈើទៅតាមរដូវកាល និងវ័យរបស់ពួកគាត់ ក្នុងតំបន់ដែលរដ្ឋាភិបាលបានសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនភាពីម៉ិក ដែលមានផ្ទៃដីសរុបចំនួន ៣១៥.០២៨ ហិកតា ។ ជាក់ស្តែងក្មេងៗ និងមនុស្សចាស់ដែលមិនអាចធ្វើការងារធ្ងន់ៗបានច្រើនគាត់បានទៅប្រមូលអនុផលព្រៃឈើដូចជារកអុស បោចវល្លិ៍ បេះផ្លែឈើព្រៃ រកផ្សិត បន្លែ និងចាប់សត្វដែលអាចធ្វើជាចំណីអាហារបានជាប្រចាំថ្ងៃ ។ សម្រាប់មនុស្សពេញវ័យ និងពេញកម្លាំងអាចធ្វើការបានជាច្រើនដូចជា ការរកឈើសម្រាប់ធ្វើលំនៅដ្ឋាន ដងជ័រទឹក រកបង្គោលរបងផ្ទះ ឈើសំណង់ និងអនុផលព្រៃឈើជាច្រើនទៀតដែលអាចរកចំណូលសម្រាប់ចិញ្ចឹមគ្រួសាររបស់ពួកគេយ៉ាងសមរម្យ ។

**ការសម្រេចផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការចូលរួមរបស់ប្រជាជន**

- នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនភាពីម៉ិក ដែលមានផ្ទៃដីទំហំ ៣១៥០២៨ ហិកតា ដោយគ្មានការពិគ្រោះយោបល់ជាមួយប្រជាជនឡើយ ហើយសូម្បីតែអាជ្ញាធរមូលដ្ឋានក៏មិនបានដឹងដែររហូតដល់ពេលក្រុមហ៊ុនចុះមកធ្វើសម្មភាពទើបទទួលបានព័ត៌មាន ។ សូមបញ្ជាក់ថា នៅឆ្នាំ ១៩៩៧ តំបន់នេះគឺជាតំបន់ប្រទាញប្រទង់គ្នា (កំពុងបាញ់គ្នា) រវាងទាហានរដ្ឋាភិបាល និងទាហានខ្មែរក្រហម ។ លើសពីនេះទៀត ការសម្បទាននេះក៏រំលោភទៅលើច្បាប់ភូមិបាលដែលបានអនុម័តនៅឆ្នាំ ២០០១ ផងដែរ ប៉ុន្តែ ត្រូវបានមន្ត្រីរដ្ឋាភិបាលលើកឡើងថា ការសម្បទាននេះកើតឡើងមុនការអនុម័តិច្បាប់ ។
- នៅឆ្នាំ ២០០០ ក្រុមហ៊ុនបានចាប់ផ្តើមធ្វើសកម្មភាពឈូសឆាយនៅឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។ សកម្មភាពរបស់ក្រុមហ៊ុនត្រូវបានដកចេញ ដោយសារតែមានការតវ៉ាពីប្រជាជន ព្រោះតំបន់នេះជាតំបន់ដែលមានឈើធំៗ (មុខកាត់ប្រហែល ២ ម៉ែត្រ) ដែលជាឈើច្បោះ (ឈើផ្តល់ជ័រទឹក) របស់ប្រជាជនរាប់ម៉ឺនដើម ហើយក៏ជាប្រភពចំណូលរបស់ពួកគាត់យ៉ាងសំខាន់បន្ទាប់ពីការធ្វើស្រែចម្ការ ។
- នៅឆ្នាំ ២០០៤ ក្រុមហ៊ុនបានមកធ្វើសកម្មភាពម្តងទៀត ដែលមានទ្រង់ទ្រាយធំជាងមុន ដែលក្នុងរយៈពេល ១ ម៉ោង គ្រឿងចក្ររបស់ក្រហ៊ុនអាចឈូសឆាយដីព្រៃបានផ្ទៃដីប្រមាណ ២០ ហិកតា ។ ម្តងនេះក៏ត្រូវប្រជាជនតវ៉ាឲ្យក្រុមហ៊ុនដកចេញជាលើកទី ២ ទៀត ។ ការតវ៉ានេះមានរយៈពេល ៤ ថ្ងៃ ដោយមានការបិទផ្លូវជាតិលេខ ៥ រយៈពេល ១ ថ្ងៃ ហើយនៅដេករង់ចាំដំណោះស្រាយ ដែលក្នុងអំឡុងពេលដែលរង់ចាំនោះ មានការបោក

គ្រាប់បែកនៅវេលាយប់ដែលធ្វើឲ្យមានអ្នករងរបស់ធ្ងន់ និងស្រាលចំនួន ៩ នាក់ ។ អ្នករងរបួសពេលដឹកទៅមន្ទីរពេទ្យខេត្តពោធិ៍សាត់ មិនត្រូវបានគ្រូពេទ្យពិនិត្យឲ្យបានដិតដល់ឡើយ ។ អ្នករបួលក៏ត្រូវបានដឹកយកទៅព្យាបាលនៅតាមមន្ទីរពេទ្យរបស់អង្គការសិទ្ធិមនុស្សនៅទីក្រុងភ្នំពេញ ។

- នៅឆ្នាំ ២០១០ ក្រុមហ៊ុនមកធ្វើសកម្មភាពជាថ្មីទៀត ដែលលើកនេះមានទ្រង់ទ្រាយធំក្រៃលែងដោយមានគ្រឿងចក្រជាច្រើនរយគ្រឿង ។ ក្រុមហ៊ុនបានប្រើល្បិចឲ្យប្រជាជននៅឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ផ្តិតមេដៃទទួលយកអំណោយរបស់រដ្ឋាភិបាល រួចបំលែងមេដៃទទួលអំណោយទៅជាការគាំទ្រឲ្យក្រុមហ៊ុនមកធ្វើសកម្មភាព ។ ម្តងនេះសហគមន៍ពុំហ៊ានធ្វើការទាមទារឡើយដោយសារតែពួកគាត់គិតថា បើតវ៉ាអាចនឹងប្រឈមការចាប់ដាក់គុកព្រោះបានផ្តិតមេដៃទទួលយកអំណោយរបស់គេហើយ ។ ព្រៃឈើ និងដីរបសហគមន៍មួយចំនួនត្រូវបានក្រុមហ៊ុនឈូសឆាយយកដើម្បីដាំដំឡូងមី ។ ប៉ុន្តែសម្រាប់សហគមន៍ដទៃទៀត នៅតែបន្តទាមទារដើម្បីការពារដីឯកជន និងទាមទារឲ្យមានព្រៃសម្រាប់បង្កើតសហគមន៍ជាបន្តបន្ទាប់ ហើយទទួលបានលទ្ធផលមួយចំនួនដូចមានរៀបរាប់សង្ខេបខាងក្រោម ។

**ផលប៉ះពាល់ផ្នែកយេនឌ័រក្រោយការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់**

- **ការរំលោភសិទ្ធិដីធ្លី និងធនធានធម្មជាតិ ៖** នៅពេលដែលក្រុមហ៊ុនភាពីម៉ិកចាប់ផ្តើមដំណើរការនៅដើមឆ្នាំ ២០១០ ក្រុមហ៊ុននេះបានរំលោភសិទ្ធិដីធ្លីជាច្រើនគ្រួសារ ។ ឃុំអន្សាចំបក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ គឺជាទីតាំងដំបូងដែលក្រុមហ៊ុនមកប្រតិបត្តិការ ហើយមានប្រជាជនជាច្រើនរយគ្រួសារបានរងផលប៉ះពាល់ដោយសារតែការឈូសឆាយយកដីធ្លីរបស់ក្រុមហ៊ុន ។ គ្រួសាររងគ្រោះដោយសារការរំលោភយកដីធ្លីពីសំណាក់ក្រុមហ៊ុនបាននាំគ្នាតវ៉ាជាញឹកញាប់ជាមួយសហគមន៍នៅក្នុងឃុំអញ្ចាញរូង ពេជចង្វារ និងត្រពាំងចាន់ ស្រុកបរិបូណ៌ ព្រមទាំងឃុំក្បាលត្រាច និងអន្លង់ត្នោត ស្រុកក្រគរ ចាប់តាំងពីឆ្នាំ ២០១០ រហូតដល់ពាក់កណ្តាលឆ្នាំ ២០១២ ទាមទារឲ្យមានការការពារដីឯកជន និងស្នើសុំព្រៃសម្រាប់បង្កើតសហគមន៍ ។ ហេតុនេះ នៅក្នុងឆ្នាំ ២០១០ មានការប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានប្រកាសផ្តល់ដីសម្រាប់បង្កើតសហគមន៍នៅតាមឃុំមួយចំនួននៅក្នុងស្រុកក្រគរ ស្រុកភ្នំក្រវ៉ាញ និងក្រុងពោធិ៍សាត់ ប៉ុន្តែការប្រកាសនោះមិនបានកំណត់ឲ្យបានជាក់លាក់នូវទីតាំងដី ទើបឃុំមួយចំនួននៅក្នុងស្រុកក្រគរមានការចង្រៃងចម្រាសរវាងសហគមន៍ និងអាជ្ញាធរមូលដ្ឋានដោះស្រាយមិនទាន់ចប់រហូតមកដល់បច្ចុប្បន្ន ។ នៅឆ្នាំ ២០១១ នៅខេត្តកំពង់ឆ្នាំង លោកអភិបាលខេត្តប្រកាសប្រាប់សហគមន៍ថានឹងដោះស្រាយបញ្ហារវាងក្រុមហ៊ុន និងសហគមន៍រួចរាល់ទើបឲ្យក្រុមហ៊ុនអនុវត្តនៅក្នុងខេត្តនេះ ។ បន្ទាប់មក នៅពាក់កណ្តាលឆ្នាំ ២០១២ ទើបមានបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាល ចាត់ឲ្យមានក្រុមនិស្សិត និងខ្សែបណ្តោយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងអាជ្ញាធរមូលដ្ឋាន ចុះវាស់វែងដីធ្លីជូន

ប្រជាជនដែលមានជម្លោះជាមួយក្រុមហ៊ុនសម្បទានទូទាំងប្រទេស ដោយទុកឲ្យមានដីព្រៃមួយចំនួនសម្រាប់បង្កើតព្រៃសហគមន៍ផងដែរ ដែលរួមទាំងនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ផងដែរ ។ ក្រោយពីអនុវត្តបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់មក ប្រជាជនដែលមានបញ្ហារំលោភដីធ្លីពីក្រុមហ៊ុនត្រូវបានដោះស្រាយស្ទើរតែទាំងស្រុង ។ ផ្ទៃដីដែលមានទំនាស់ជាច្រើនម៉ឺនហិកតា ត្រូវបានវាស់វែងជូនប្រជាជននៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ហើយបានទុកដីព្រៃមួយចំនួនសម្រាប់បង្កើតសហគមន៍ ដោយឲ្យរៀបចំសហគមន៍តាមដំណើរការ និងគោលការណ៍ណែនាំរបស់រដ្ឋបាលព្រៃឈើ ។ បើនិយាយអំពីធនធានធម្មជាតិវិញ ព្រៃឈើនៅក្នុងតំបន់ដីសម្បទានសេដ្ឋកិច្ចត្រូវបានឈូសឆាយទាំងស្រុងដើម្បីដាំដំឡូងមី និងដើមអាកាស្យា ។ ក្រោយមក ក្រុមហ៊ុនកំទេចដើមអាកាស្យាចោលក្រោយពីដាំបានរយៈពេល ១ ឆ្នាំ ហើយយកដីនោះដាំដំឡូងមីទាំងអស់វិញ ។ ចំពោះផ្លូវទឹកធម្មជាតិ ដូចជាអូរ ស្ទឹង ព្រែក ត្រូវបានក្រុមហ៊ុនលុប និងបង្វែរទិសទឹកហូរ ព្រមទាំងប្រើប្រាស់ជីគីមី និងថ្នាំពុលសម្រាប់ការពារដំឡូងមីបង្ហូរចូលទឹកទាំងនោះ ធ្វើឲ្យទឹកមានជាតិពុល មិនអាចឲ្យប្រជាជនដែលធ្លាប់ប្រើប្រាស់ទឹកនោះប្រើបានទៀតឡើយ ។ ចំណែកឯសត្វព្រៃគ្រប់ប្រភេទត្រូវបានបាត់បង់ស្ទើរគ្មានសល់ដោយសារតែការបរបាញ់ និងការបាត់បង់ទីជម្រក ។

- **ផលប៉ះពាល់លើមនុស្សចាស់ ជនពិការ ស្ត្រីមេម៉ាយ និងកុមារ**
  - បាត់បង់មុនរបរ និងប្រាក់ចំណូល ៖ មនុស្សចាស់ ជនពិការ ស្ត្រីមេម៉ាយ និងកុមារដែលមានចំនួនប្រមាណ ៥០ ទៅ ៦០ ភាគរយនៃប្រជាជនសរុបនៅតាមឃុំនីមួយៗ ដែលធ្លាប់រកចំណូលបានមួយចំនួនពីតំបន់ព្រៃដែលនៅជិតលំនៅដ្ឋានរបស់ខ្លួនតាមរយៈការរកអនុផលព្រៃឈើដូចជាបន្លែ ផ្លែឈើ ផ្សិត ទំពាំង និងអនុផលច្រើនទៀត ។ ក្រោយពេលក្រុមហ៊ុនបានឈូសឆាយព្រៃអស់ ហើយមិនអនុញ្ញាតឲ្យសហគមន៍ចូលទៅក្នុងកន្លែងដែលក្រុមហ៊ុនដាំដំឡូងដោយសេរីដូចកាលពីមុន ពួកគាត់បានបាត់បង់ចំណូលពីព្រៃឈើទាំងស្រុង ។ ហេតុនេះ ការអភិវឌ្ឍន៍ដែលមិនបានពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយលើយេនឌ័រ និងមិនបានរកដំណោះស្រាយឲ្យបានសមស្របធ្វើឲ្យមនុស្សមួយក្រុមធំនៅក្នុងសហគមន៍ជនបទ ជាពិសេសតំបន់ដែលប្រជាជនរស់នៅពឹងផ្អែកលើធនធានធម្មជាតិបាត់បង់មុខរបរ និងប្រភពចំណូលមួយយ៉ាងសំខាន់ ដែលអាចជម្រុញឲ្យពួកគាត់ធ្លាក់ក្នុងអន្លង់នៃភាពក្រីក្រ ហើយបង្កបញ្ហាដល់សង្គមជាច្រើនទៀតនៅពេលអនាគត ។
  - បាត់បង់ម្ហូបអាហារប្រចាំថ្ងៃដែលបានមកពីអនុផលព្រៃឈើ និងបង្កើនចំណាយខ្ពស់លើម្ហូបអាហារប្រចាំថ្ងៃ ៖ អនុផលព្រៃឈើគឺជាប្រភពអាហារប្រចាំថ្ងៃយ៉ាងច្រើនសន្ធឹកសន្ធាប់របស់ប្រជាជនដែលរស់នៅអាស្រ័យលើធនធានព្រៃឈើ និងធនធានធម្មជាតិ ។ ដូចបានរៀបរាប់ខាងលើ អនុផលព្រៃឈើទាំងនេះ ប្រជាជនបានទៅអាស្រ័យផលដោយពុំបាច់ចំណាយប្រាក់កាស ឬធនធានអ្វីច្រើន ឬគិតពី

មនុស្សពេញវ័យឡើយ សូម្បីតែជនងាយរងគ្រោះដូចជា ជនពិការ មនុស្សចាស់ កុមារដែលទំនេរពីការសិក្សា គឺគ្រាន់តែចំណាយពេលវេលាមួយចំនួនពួកគេអាច រកម្ហូបបានដោយងាយពីព្រៃឈើដែលនៅជិតភូមិស្ថានរបស់ពួកគេ ។ ផ្ទុយទៅវិញ នៅពេលដែលក្រុមហ៊ុនសម្បទានបានឈូសឆាយតំបន់ព្រៃ ហើយប្រែក្លាយតំបន់នេះឲ្យទៅជាចំការឈើដាំ នោះអនុផលទាំងនោះបានបាត់បង់ស្ទើរគ្មានសល់ ដែលជាហេតុធ្វើឲ្យប្រជាជនបាត់បង់ប្រភពម្ហូបអាហាររបស់ពួកគាត់ ។ ម៉្យាងវិញទៀត បើទុកជាបាត់បង់ប្រភពអាហារដែលបានមកពីតំបន់ព្រៃឈើ ប៉ុន្តែការហូបចុករបស់មនុស្សមិនបានថយចុះ ឬឈប់បរិភោគតាមការបាត់បង់ប្រភពអាហារដែលធ្លាប់អាស្រ័យបានឡើយ ។ ហេតុនេះ ប្រជាជនត្រូវចំណាយថវិកាទៅទិញម្ហូបអាហារនៅទីផ្សារមានតំលៃខ្ពស់ឡើងៗជាប្រចាំ ។ ជាមួយគ្នានេះដែរ ម្ហូបអាហារលក់នៅទីផ្សារត្រូវបានគេប្រើប្រាស់សារធាតុគីមីជាច្រើនដើម្បីបង្កើនទិន្នផល និងរក្សាទុកបានយូរ ដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរ ។ ហេតុដូច្នេះ ប្រជាជនមិនត្រឹមតែចំណាយច្រើនលើការទិញម្ហូបអាហារប៉ុណ្ណោះទេ គឺថែមទាំងត្រូវចំណាយបន្ថែមលើការព្យាបាល និងថែទាំសុខភាពផងដែរ ។

- **ផលប៉ះពាល់លើមនុស្សពេញវ័យ និងពេញកម្លាំង ៖** ទន្ទឹមនឹងការបាត់បង់ចំណូលរបស់ក្រុមងាយរងគ្រោះនៅក្នុងសហគមន៍ មនុស្សពេញវ័យដែលមានចំនួនប្រមាណពី ៤០ ទៅ ៥០ ភាគរយនៃប្រជាជនសរុបតាមឃុំនីមួយៗក៏ទទួលផលប៉ះពាល់យ៉ាងខ្លាំងផងដែរ ក្រោយពីមានការផ្តល់ដីសម្បទានសេដ្ឋកិច្ច ។ ពួកគេត្រូវប្រើប្រាស់ពេលវេលាច្រើនជាងមុនពី ៣ ទៅ ៤ ដង ដើម្បីទទួលបានផល ឬអនុផលព្រៃឈើដែលពួកគេធ្លាប់ទទួលបានកន្លងមក ដោយសារតែធនធានព្រៃឈើនៅជិតតំបន់របស់ខ្លួនរស់នៅត្រូវបាត់បង់ និងធ្វើដំណើរទៅកន្លែងឆ្ងាយជាងមុនរាប់សិបគីឡូម៉ែត្រ ។ ជាក់ស្តែង សហគមន៍នៅឃុំអញ្ចាញរូង និងឃុំពេជចង្វារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ដែលត្រូវរកឈើសម្រាប់ធ្វើផ្ទះសម្បែងត្រូវធ្វើដំណើរឆ្លងភ្នំជាច្រើនខ្នងដែលស្ថិតនៅទឹកដីស្រុកភ្នំក្រវ៉ាញ ឬស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលមានចំងាយលើសពី ១០០ គីឡូម៉ែត្រ ។ ក្រៅពីនេះ ពួកគេធ្លាប់បានដកហូតផលព្រៃឈើ និងអនុផលសំខាន់ៗដូចជាជ័រទឹក បង្គោលរបង រុក្ខជាតិឱសថ និងបន្លែផ្លែឈើព្រៃជាដើមសម្រាប់លក់ក៏ត្រូវបានបាត់បង់ ។ សម្រាប់មនុស្សពេញវ័យ ឬពេញកម្លាំង ក្រៅពីការធ្វើស្រែ ពួកគេរកចំណូលពីព្រៃឈើជាង ៤០ ភាគរយនៃចំណូលសរុបប្រចាំឆ្នាំ ។ បើតាមការប៉ាន់ប្រមាណ ចំណូលរបស់ប្រជាជនមានចន្លោះពី ៤០០០ ដុល្លារ ទៅ ៦០០០ ដុល្លារ អាមេរិក ក្នុងមួយឆ្នាំ អាស្រ័យតាមគ្រួសារតូច ឬធំ ។ ជាក់ស្តែង ប្រសិនបើកាលពីពេលដែលមានធនធានធម្មជាតិ ពួកគាត់អាចរកចំណូលបានពី ២០០០ ដុល្លារ ក្នុង ១ ឆ្នាំពីព្រៃ នោះបច្ចុប្បន្ន ពួកគេអាចរកបានត្រឹមតែពី ៥០០ ដុល្លារ ទៅ ១០០០ ដុល្លារ យ៉ាងច្រើនបំផុត ។
- **ចំណាកស្រុក ៖** យោងតាមការលើកឡើងរបស់មេឃុំតាមឃុំនីមួយៗ នៅមុនឆ្នាំ ២០១០ (មុនពេលក្រុមហ៊ុនមកប្រតិបត្តិការ) ការចាកចេញពីស្រុករបស់ប្រជាជននៅក្នុងឃុំ

នីមួយៗដើម្បីទៅរកការងារធ្វើក្រៅស្រុកភូមិរបស់ខ្លួនមានតិចតួចបំផុតប្រហែលមិនលើសពី ២០ នាក់ក្នុងមួយឃុំៗ ។ បន្ទាប់ពីក្រុមហ៊ុនបានមកប្រតិបត្តិការឈូសឆាយព្រៃឈើដើម្បីដាំដំឡូងមី ដែលធ្វើឲ្យបាត់បង់នូវធនធានដែលពួកគាត់ធ្លាប់អាស្រ័យផល បានធ្វើឲ្យប្រជាជនធ្វើការចាកចេញពីស្រុកកាន់តែច្រើនឡើងៗ ដែលបច្ចុប្បន្នក្នុងមួយឃុំៗមានចន្លោះពី ៣០០ នាក់ ទៅ ៥០០ នាក់ ហើយភាគច្រើនជាបុរស ដែលនិន្នាការនៃចំណាកស្រុកកាន់តែច្រើនឡើងៗជាលំដាប់ ។ ការចាកចេញពីស្រុកនេះគឺដើម្បីទៅស្វែងរកការងារធ្វើដែលភាគច្រើនទៅធ្វើការនៅតាមទីក្រុង និងប្រទេសជិតខាងជាពិសេសប្រទេសថៃ ហើយមួយចំនួនតូចទៅធ្វើការនៅចំការដំឡូងរបស់ក្រុមហ៊ុន ឬរបស់ឯកជនតាមតំបន់ព្រំដែន ។ ចំពោះការចាកចេញពីស្រុកទៅធ្វើការនៅតាមប្រទេសជិតខាងរបស់ប្រជាជនភាគច្រើនគឺការចំណាកស្រុកដោយខុសច្បាប់ (តាមរយៈមេខ្យល់នាំយកទៅធ្វើការ) ដែលបង្កឲ្យពួកគេពុំមានសុវត្ថិភាពក្នុងធ្វើការដោយប្រឈមនឹងការបោកប្រាស់ ឬចាប់ខ្លួនដាក់ពន្ធនាគារជាដើម ។

- **ការបង្កើនបន្ទុកដល់ស្ត្រីនៅពេលបុរសទៅធ្វើការឆ្ងាយផ្ទះ និងធនធានធម្មជាតិដែលប្រើប្រាស់ជាប្រចាំបាត់បង់អស់ ៖** ក្រោយពេលបុរសភាគច្រើនដែលជាមនុស្សពេញកម្លាំង និងមេគ្រួសារមួយចំនួនធំបានចាកចេញពីផ្ទះដើម្បីទៅរកការងារធ្វើ ស្ត្រីជាមេផ្ទះត្រូវទទួលរងបន្ទុកជាច្រើននៅក្នុងគ្រួសារ ។ ស្ត្រីត្រូវធ្វើការមួយចំនួនបន្ថែមទៀតដែលជាការងារធ្ងន់ៗក្រៅពីការងារដែលខ្លួនធ្លាប់ធ្វើកន្លងមក ដោយសារតែបុរសមិននៅផ្ទះ ។ ស្ត្រីនៅផ្ទះត្រូវមើលថែទាំកូន ឪពុកម្តាយចាស់ៗ និងត្រូវធ្វើការងារស្រែចំការ ។ ហេតុនេះ ស្ត្រីដែលគ្រួសារទៅចំណាកស្រុកពុំសូវបានចូលរួមក្នុងសកម្មភាពសង្គម ដែលធ្វើឲ្យពួកគេបាត់បង់ឱកាសក្នុងការចូលរួម និងការសម្រេចចិត្តលើការងារផ្សេងៗរបស់សហគមន៍ ដែលជួនកាលពួកគេត្រូវរងគ្រោះដោយសារការសម្រេចចិត្តជំនួសពីអ្នកដទៃ ។ ម៉្យាងវិញទៀត ស្ត្រីអាចប្រឈមនឹងបញ្ហាគ្រោះថ្នាក់ផ្សេងៗទៀត ក្នុងករណីមានការរំលោភសិទ្ធិមនុស្សជាច្រើនករណី ដោយសារតែស្ត្រីជាភេទទន់ខ្សោយ ។ លើសពីនេះ ការបាត់បង់ធនធានធម្មជាតិដែលជារបស់របរដែលពួកគាត់ធ្លាប់ប្រើប្រាស់ជាប្រចាំដូចជា អុស បន្លែ អាហារប្រចាំថ្ងៃ បានធ្វើឲ្យស្ត្រីត្រូវមានការចំណាយកាន់តែច្រើន ហើយព្យាយាមសន្សំសំចៃដើម្បីធានាសមតុល្យរវាងចំណូល និងចំណាយឲ្យបានត្រឹមត្រូវ និងជៀសវាងការចំណាយលើសចំណូល ឬជំពាក់បំណុលគេ ។
- **អត្រានៃការបោះបង់ការសិក្សារបស់កុមារ និងយុវវ័យមានការកើនឡើង ៖** ក្រោយពីមានសកម្មភាពរបស់ក្រុមហ៊ុនឈូសឆាយព្រៃឈើ ដែលធ្វើឲ្យបាត់បង់នូវធនធានធម្មជាតិ និងអនុផលព្រៃឈើដែលកុមារ និងយុវវ័យ អាចជួយគ្រួសារក្នុងការរកចំណូល ឬរករបស់របរប្រើប្រាស់ប្រចាំថ្ងៃរបស់គ្រួសារដូចជា បន្លែ ផ្លែឈើ អុស និងចំណីអាហារជាច្រើនប្រភេទដែលបានមកពីតំបន់ព្រៃឈើ និងជួយកាត់បន្ថយចំណាយជាច្រើនក្នុងគ្រួសារ ពួកគេបានសម្រេចចិត្តបោះបង់ការសិក្សាដើម្បីទៅធ្វើការនៅតាមទីក្រុង ឬតាមរោងចក្រកាត់ដេរដើម្បីជួយរកប្រាក់កំរៃដើម្បីទប់ទល់នឹងការចំណាយរបស់គ្រួសារ ។ បើយោងតាមរបាយ

ការណ៍របស់ឃុំ អត្រារបស់កុមារដែលបោះបង់ការសិក្សាខ្ពស់គឺសិស្សដែលរៀនបានដល់ថ្នាក់ទី ៥ ឬទី ៦ ឡើងទៅ ។ អត្រានៃការបោះបង់ការសិក្សារបស់កុមារមានក្នុងចន្លោះពី ៣០ ភាគរយ ទៅ ៣៥ ភាគរយ ។